**សាររំលែកទុក្ខពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាទៅដល់ក្រុមគ្រួសារជនរងគ្រោះ នៅក្នុងឧបទ្ទវហេតុនៅលើស្ពានកោះពេជ្រ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០**

<u>ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១០</u>

បុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងអស់នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) សូមសម្តែងនូវការសោកស្តាយ និងចូលរួមរំលែកមរណទុក្ខជាមួយក្រុមគ្រួសារនៃជនរងគ្រោះក្នុងសោកនាដកម្មលើស្ពានកោះពេជ្រ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០។ យើងខ្ញុំទាំងអស់គ្នាជឿជាក់ថា ការចូលរួមរំលែកទុក្ខគ្រប់រូបភាពពីសំណាក់ប្រជាពលរដ្ឋកម្ពុជាទាំងអស់នឹងជាកម្លាំងចិត្តជួយដល់គ្រួសារជនរងគ្រោះឲ្យឆ្លងកាត់កាលៈទេសៈដ៏លំបាកនេះ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងបិទការិយាល័យរបស់ខ្លួន នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ដើម្បីចូលរួមគោរពថ្ងៃកាន់ទុក្ខជាតិ និងសម្តែងនូវការរំលែកទុក្ខរបស់យើងខ្ញុំទៅដល់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគាត់។

សូមអោយវិញ្ញាណក្ខ័ន្ធរបស់លោកអ្នកទាំងឡាយបានទៅដល់សុគតិភព។#

អ៊ូ វីរៈ#<br>
ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា